# ខ្មែរក្រៅស្រុកបង្កើតគណៈកម្មការស៊ើបអង្កេតការ

28 តុលា 2021 ដឹង ប៉ូដឺន |អត្ថបទដកស្រង់

វ៉ាស៊ីន តោន —

កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសដែលត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី២៣ខែតុលាឆ្នាំ១៩៩១បានបញ្ចប់នូវការកាប់សម្លាប់គ្នារវាងខ្មែរនិងខ្មែរអស់រយៈពេលជិត២ទសវត្សរ៍ដែលបានចាប់ផ្តើមដោយមានរបបវាលពិឃាតខ្មែរក្រហមដែលបានចូលកាន់អំណាចនៅក្នុងឆ្នាំខែមេសាឆ្នាំ១៩៧៥។

របបប្រល័យពូជសាសន៍ខ្មែរក្រហមបានកាប់សម្លាប់ពលរដ្ឋកម្ពុជារហូតដល់ជិត២លាននាក់ តាមរយៈការធ្វើឃាតការបង្អត់អាហារនិងធ្វើពលកម្មហួសកម្លាំងមុនការចូលឈ្លានពានរបស់វៀតណាមដែលបានផ្តួលរំលំរបបខ្មែរក្រហមកុម្មុយនីស្តហើយបានធ្វើឲ្យមាន  សង្គ្រាមស៊ីវិលមួយកើតឡើង។

កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសបានត្រួសត្រាយផ្លូវឲ្យមានការបោះឆ្នោតតាមបែបលទ្ធិ ប្រជាធិបតេយ្យលើកដំបូងនៅក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៩៣ហើយនាំទៅដល់ការបញ្ចប់ប្រកបដោយប្រសិទ្ធភាពនូវសង្គ្រាមត្រជាក់ក្នុងតំបន់អាស៊ីផងដែរ។ជំនួយពីប្រទេសលោកខាងលិចចាប់ផ្តើមហូរចូលប្រទេសកម្ពុជាហើយកម្ពុជាត្រូវបានគេប្រកាសថាជាប្រទេសក្មេងមួយក្រោយអន្តរកាលនៃជម្លោះឆ្ពោះទៅកាន់លទ្ធិប្រជាធិបតេយ្យមួយ។

កាលពីថ្ងៃទី២៣ខែតុលាកន្លងទៅនេះអង្គការ Khmer Network បានរៀបចំពិធីតាម អនឡាញមួយដែលរំលឹកពីប្រវត្តិនៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសនេះ។ វាគ្មិនទាំងនោះ ភាគច្រើនជាវេជ្ជបណ្ឌិតទន្តពេទ្យនិងបញ្ញវន្តខ្មែរដែលរស់នៅក្នុងសហរដ្ឋអាមេរិកនិងនៅប្រទេសបារាំង។ អង្គការនោះក៏បានបង្កើតគណៈកម្មការស៊ើបអង្កេតសម្រាប់កម្ពុជាឬ Commission of Inquiry for Cambodia ដែលបានប្រមូលចងក្រងអំពីការរំលោភសិទ្ធិមនុស្ស ការរំលាយលទ្ធិប្រជាធិបតេយ្យការចាប់ឃុំឃាំងនិងការសម្លាប់សមាជិកគណបក្សប្រឆាំងនិងសកម្មជនសិទ្ធិមនុស្ស។

ទន្តពេទ្យចូលនិវត្តន៍លោកស្រី Nicole Ung បានមានប្រសាសន៍ថា គោលបំណងនៃការបង្កើតគណៈកម្មការស៊ើបអង្កេតនេះឡើងក៏ដើម្បីធ្វើការទាក់ទាញពីសំណាក់អន្តរជាតិឲ្យចាប់អារម្មណ៍និងយកចិត្តទុកដាក់ពីការអនុវត្តនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសពីរដ្ឋាភិបាលកម្ពុជាផងដែរ។

លោកស្រីបានថ្លែងថា៖ «ចំពោះគណៈកម្មការស៊ើបអង្កេតសម្រាប់កម្ពុជាមានភារកិច្ចស្តាប់សាកសួរនិងប្រមូលអង្គហេតុទាំងអស់ទាក់ទងនឹងការអនុវត្តនិងការរំលោភកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១និងសន្ធិសញ្ញាអន្តរជាតិដទៃទៀតដែលកម្ពុជាបានចុះហត្ថលេខា»។

នៅខែវិច្ឆិកាឆ្នាំ២០១៧ តុលាការកំពូលបានរំលាយគណបក្សសង្គ្រោះជាតិដែលជាគណបក្សប្រឆាំងដ៏សំខាន់មួយនៅក្នុងប្រទេសកម្ពុជាក្រោមការចោទប្រកាន់ថាមានគោលបំណងផ្តួលរំលំរដ្ឋាភិបាលរបស់លោកហ៊ុនសែន។

ចាប់តាំងពីការបោះឆ្នោតនៅខែកក្កដាឆ្នាំ២០១៨មកគណបក្សប្រជាជនកម្ពុជារបស់លោក ហ៊ុន សែន បានកាន់កាប់អាសនៈទាំងអស់នៅក្នុងសភា។ ពួកអាជ្ញាធរបានចាប់ខ្លួនអតីតសមាជិកគណបក្សប្រឆាំងនិងអ្នកធ្វើយុទ្ធនាការដើម្បីសិទ្ធិមនុស្ស។

ពួកសកម្មជនគណបក្សសង្គ្រោះជាតិជាង១៥០នាក់ប្រឈមនឹងការកាត់ទោសលើបទចោទប្រកាន់ពាក់ព័ន្ធនឹងសកម្មភាពញុះញង់ និងការក្បត់ជាតិ។លោកកឹម សុខាដែលជាមេដឹកនាំគណបក្សប្រឆាំងដ៏សំខាន់កំពុងប្រឈមការកាត់ទោសពីការក្បត់ជាតិដែរ។ លោក Gareth Evans អតីតរដ្ឋមន្ត្រីការបរទេសអូស្ត្រាលីនិងជាស្ថាបនិកកិច្ចព្រមព្រៀងនោះ បានប្រាប់ទីភ្នាក់ងារព័ត៌មាន AFP ដែលបានចុះផ្សាយកាលពីថ្ងៃទី២០ខែតុលានេះថា៖ «យើងបានធ្វើការងារនេះយ៉ាងល្អអំពីការធ្វើឲ្យមានសន្តិភាពប៉ុន្តែបានបរាជ័យអំពីលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស»។

លោក Evans បានថ្លែងបន្តទៀតថាវាជាកំហុសមួយដែលបានយល់ព្រមទៅតាមការទាមទាររបស់លោកហ៊ុនសែន ក្នុងការចែករំលែកអំណាចក្រោយការបោះឆ្នោតឆ្នាំ១៩៩៣នោះបន្ទាប់ពីលោកហ៊ុន សែនបានចាញ់ឆ្នោត។

ការកាន់អំណាចរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលកាន់អំណាចអស់រយៈពេលជិត៤០ឆ្នាំកន្លងទៅនេះបានដឹកនាំការ បង្ក្រាបទៅលើក្រុមប្រឆាំងឥតឈប់ឈរ។

សកម្មជនខ្មែរអាមេរិកាំងប្រារព្ធខួបទី៣០នៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសដោយបាតុកម្មនៅរដ្ឋធានីវ៉ាស៊ីនតោន។

លោក ឡុង បូតា ជាសមាជិកជាន់ខ្ពស់របស់គណបក្សសង្គ្រោះជាតិនិងជាវាគ្មិននៅក្នុងការពិភាក្សានោះដែរ បានសម្តែងនូវការមិនពេញចិត្តចំពោះការបោះឆ្នោតចាប់តាំងពីឆ្នាំ១៩៩៣នៅក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិមក។ លោក បានថ្លែងថា គណបក្សទាំងអស់បានរងការបំភិតបំភ័យពីគណបក្សកាន់អំណាចហើយដែលនៅទីបំផុតគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនារបស់លោកតាសឺន សាននិងគណបក្សហ៊្វុនស៊ិន ប៉ិចបានត្រូវកម្ទេច។

លោក បានថ្លែងថា៖ «ថ្វីបើយើងមានការរិះគន់អំពីរឿងការបោះឆ្នោតក្រោមអង្គការសហប្រជាជាតិអ៊ុនតាក់នៅឆ្នាំ១៩៩៣ដែលខ្ញុំហើយនឹងភរិយាខ្ញុំបានចូលរួមជាបេក្ខភាពដែរនោះ វាមិនមានការត្រឹមត្រូវ។ពួកកុម្មុយនីស្តបានបំផ្លាញទាំងអស់គណបក្សសេរីនិយមនោះ»។

លោក យោ អេង ហ៊ន វេជ្ជបណ្ឌិតខ្មែរដែលចូលនិវត្តន៍រស់នៅក្នុងប្រទេសបារាំង បានជំរុញលើកទឹកចិត្តប្រជាពលរដ្ឋខ្មែរឲ្យសិក្សានិងស្វែងយល់អំពីប្រវត្តិសាស្ត្ររបស់ខ្លួននិង ខិតខំរៀន សូត្រដើម្បីជួយកសាងប្រទេសរបស់ខ្លួន។ លោកបានថ្លែងថា យុវជនខ្មែរត្រូវតែសិក្សា ពីប្រវត្តិសាស្ត្រជៀសវាងពីការបោកប្រាស់ និងការបំភ្លៃប្រវត្តិ

សាស្ត្រពី ប្រទេសជិតខាងរបស់ខ្លួនហើយនឹងប្រកាន់ខ្ជាប់និងគោរពសន្ធិសញ្ញាអន្តរជាតិ ដូចជាកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស។
លោកបានទាមទារឲ្យ លុបចោលសន្ធិសញ្ញាទ្វេភាគីរវាងកម្ពុជានិងវៀតណាម ដែលបានធ្វើឡើងមុនកិច្ចព្រមព្រៀងទីក្រុងប៉ារីសនេះ។

លោកបានថ្លែងថា៖ «ក្រោមការកាប់សម្លាប់នៃបនខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៥និងក្រោមលេសជួយរំដោះដើម្បីឆ្លៀតឱកាសចូលឈ្លានពានកម្ពុជាពីសំណាក់ប្រទេសវៀតណាមអង្គការសហប្រជាជាតិ បានសម្រេចនូវផែនការបង្រួបបង្រួមជាតិមួយនៅថ្ងៃទី២៣ ខែតុលា១៩៩១ ដែលហៅថា កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដែលមានប្រទេស១៩ជាត្តលេខីទទួលស្គាល់ រួមទាំងកម្ពុជាផងដែរ។

កិច្ចព្រមព្រៀងនេះអមដោយរដ្ឋធម្មនុញ្ញតាមបែបប្រជាធិបតេយ្យថ្មីមួយ មានគោលបំណងកសាងកម្ពុជាដែលរងគ្រោះបំផ្លាញកន្លងមកឲ្យក្លាយជាប្រទេសពេញសិទ្ធិឡើងវិញធានានូវអធិបតេយ្យភាពឯករាជ្យភាពបូរណភាពទឹកដីនិងឯកភាពនៃកម្ពុជា»។

ស្របពេលជាមួយគ្នានោះដែរ សមាគមខ្មែរនៅក្នុងប្រទេសអូស្ត្រាលីក៏បានរៀបចំពិធីដើម្បីរំឭកកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសផងដែរ ដោយមានការចូលរួមពីអតីតរដ្ឋមន្ត្រីការ បរទេសអូស្ត្រាលីលោក ដែលជាស្ថាបនិកម្នាក់នៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសនេះ។

អង្គការសិទ្ធិមនុស្សទាំងនៅក្នុងស្រុកនិងអន្តរជាតិបានសម្តែងនូវ ការខកចិត្តចំពោះបញ្ហាសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យនៅ កម្ពុជា។ ដោយឡែក អង្គការសិទ្ធិមនុស្ស Human Rights Watch ដែលមានទីតាំងនៅក្នុងសហរដ្ឋអាមេរិក បានរាយការណ៍ថានៅក្រោមការដឹកនាំរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន សូម្បីតែលទ្ធិប្រជាធិតេយ្យនិងសិទ្ធិមនុស្សបន្តិចបន្តួច បានដួលរលំ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។

បើតាមអង្គការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានរាយការណ៍ថាគេឃើញមានការបង្ក្រាបកាន់តែខ្លាំងឡើងក្នុងអំឡុងនៃការរាត្បាតជំងឺកូវីដ១៩នេះដោយមានមនុស្សជាង១០០នាក់បានត្រូវចាប់ខ្លួននិងចោទប្រកាន់ថារំលោភច្បាប់កូវីដ។

គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានព្រមានថា អ្នកទាំងនោះមិនបានទទួលការកាត់ទោសឲ្យបានត្រឹមត្រូវទេ៕